**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

គាំពារសង្គមកម្ពុជា

SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៥៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ២ ៨១២នាក់ នៃរោងចក្រ សហគ្រាសទាំង២០ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៧នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីងនឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី៥ ខែមេសា ឆ្នាំ២០២១។

ក្រសួងសូមរំឭកថា ធនាគារឯកទេសវីងនឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង២០ នេះ មិនបានទទួលសារទូរសព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

## ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

## បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ២០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 7 |
| 1 | ក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ដាប់ប៊ីលយូ អ៊ែនដ៍ ឌី កម្ពុជា | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ថប សេនធ័រ មេនូហ្វេកធឺរីង | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ជីន លូន អេហ្វ្រីខលឈ័រ | ភ្នំពេញ |
| 5 | ក្រុមហ៊ុន ញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្ដាល |
| 6 | ក្រុមហ៊ុន ស្មាតស៊ើតស៍ ហ្គាមេន មេនូហ្វេកធើរីង (ខេមបូឌា) | កំពង់ស្ពឺ |
| 7 | ក្រុមហ៊ុន វីនតាយ សកខ៍ មេនូហ្វេឈ័រ អិលធីឌី | តាកែវ |
| ខ. វិស័យទេសចរណ៍ | | 13 |
| 8 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 9 | ក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្តូរ៉ង់ | សៀមរាប |
| 10 | ក្រុមហ៊ុន វីត្រូ អ៊ិនវេសមេន | សៀមរាប |
| 11 | ក្រុមហ៊ុន ដឺ សុទ្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី | សៀមរាប |
| 12 | ក្រុមហ៊ុន ខមហ្វតប្រឌីធី ស៊ីលូសិន (ខូអិល ធីឌី) | សៀមរាប |
| 13 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 14 | ក្រុមហ៊ុន ម៉េម៉ង់ អង្គរ | សៀមរាប |
| 15 | ក្រុមហ៊ុន ញូវ រីវើរ សាយ | សៀមរាប |
| 16 | ក្រុមហ៊ុន ឡាយ ហ្គូលយ៉ាណា អង្គរ ហូថេល ឯ.ក | សៀមរាប |

| ល.រ | ឈ្មោះពេទចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 17 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 18 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 19 | ក្រុមហ៊ុន សាលាឡុង | សៀមរាប |
| 20 | រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |